# វិធីដោះស្រាយបញ្ហាការបង្វិលប្រើឡើងវិញ






## ដបប្លាស្ទីក និងប្រអប់ ឬធុងអ្វីៗសំរាប់ដាក់?

សាលាក្រុងជាច្រើនប្រមូលយកដបប្លាស្ទីកនិងប្រអប់ ឬធុងអ្វីៗដែលមាន សញ្ញា ♳ ♴ ឬ Ⓡ។ សាលាក្រុងជាច្រើនទៀតក៏ទទួលសញ្ញា ♵ ♶ ♷ ♸ និង / ឬ ♹ សូមបញ្ជាក់ជាមួយសាលាក្រុងប្រសិនបើអ្នកមិនច្បាស់លាស់។

## កែវបែក ចាន កញ្ចក់?



យកបង្វិលប្រើឡើងវិញតែដបកែវ និងក្រឡ។ កែវបែកនិងចាន ត្រូវបោះ ចោលដោយប្រយ័ត្ន ទៅក្នុងធុងសំរាមរបស់អ្នក។




## ធុងថ្នាំពណ៌?

ប្រសិនបើធុងថ្នាំពណ៌នោះទទេហើយស្ងួត យកគ្របចេញ ហើយដាក់នៅ ធុងសំរាមសំរាប់បង្វិលប្រើឡើងវិញតាមចិញ្ចើមថ្នល់។ ឬមួយមើលតាម www.cleanout.com.au សំរាប់រកកន្លែងដែលអាចដាក់ចោល។

## ប្រេង?

ប្រេងម៉ាស៊ីនឡានអាចបង្វិលប្រើឡើងវិញ ដែលមានកន្លែងសំរាប់លោកអ្នក យកទៅចោលនៅតាមមណ្ឌលគ្រប់គ្រងសំរាម (Waste management centres) ភាគច្រើន។




## ប្រអប់ភីហ្សា Pizza boxes?

ប្រអប់ភីហ្សាទទេ អាចបង្វិលប្រើឡើងវិញ ហេតុដូច្នេះ សូមដាក់វាចូល ក្នុងធុងសំរាមសំរាប់បង្វិលប្រើឡើងវិញ។



## ថង់ប្លាស្ទីក?

ថង់ប្លាស្ទីកជាគ្រឿងអាក្រក់បំផុត ធ្វើឲ្យប្រឡាក់ដល់បរិយាកាស។ មិនត្រូវដាក់វាចូលក្នុងធុងសំរាប់បង្វិលប្រើឡើងវិញទេ។



## វត្ថុស្រួច?

ម្ជុលសំរាប់ចាក់ មិនអាចបង្វិលប្រើឡើងវិញទេហើយត្រូវបោះចោលក្នុងធុង ពិសេសសំរាប់បោះចោលវត្ថុស្រួច។ មិនត្រូវដាក់ម្ជុលចូលក្នុងធុងសំរាប់បង្វិលប្រើឡើងវិញទេ។

## សំរាប់ពត៌មានបន្ថែមទៀតចូរមើលក្នុងកំព្យូទ័រ

www.environment.nsw.gov.au
www.livingthing.net.au

## ទាក់ទងទៅ

OEH Environment line 131 555

បោះពុម្ពដោយក្រសួងបរិយាការនិងផ្នែកផ្លាស់ប្តូរធាតុអាកាសនៃរដ្ឋញ.ស.វ.
Office of Environment and Heritage
Department of Premier and Cabinet
59–61 Goulburn Street, Sydney
ទូរស័ព្ទ: (02) 9995 5000 (switchboard)
ហ្វាក់ស្ស: (02) 9995 5999
TTY: (02) 9211 4723
Email: info@environment.nsw.gov.au

OEH 2011/0088 ISBN 978 1 74293 129 6 May 2011 KHMER

NSW GOVERNMENT | Office of Environment & Heritage

our environment it's a living thing



# ការសំអាត "បៃតង" ដោយងាយស្រួល

បង្កើតនូវរមណីយោទ្យានរបស់អ្នក

# ពាក្យព្រលយ ៤ ដើម្បីធ្វើជាអ្នកបង្វិលប្រើឡើងវិញដ៏ល្អពិសេស

អូស្រ្តាលីចូលចិត្តការបង្វិលប្រើឡើងវិញ។ តាមពិតយើងជាប្រទេសមួយល្អបំ ផុតក្នុងពិភពលោកក្នុងផ្នែកការបង្វិលប្រើឡើងវិញ។ នេះជាពាក្យព្រលយខ្លះៗសំរាប់ជួយលោកអ្នក។

ការបង្វិលប្រើឡើងវិញ ជាការសន្សំធនធាន ជៀសជាងការបោះចោលទៅ ក្នុងកន្លែងបំពេញដី។ វាក៏ជាការសន្សំថាមពល និងទឹក ព្រមទាំងបន្ថយធាតុ ការបោន **(carbon)** ដែលធ្វើឲ្យកខ្វក់ដល់បរិយាការ។




## ១ ចែករំលែកវត្ថុទាំងអស់

វាជាការងាយស្រួល






## ២ មិនយកថង់ប្លាស្ទីក

អូស្រ្តាលីប្រើ និងបោះចោលថង់ប្លាស្ទីកចំនួនប្រហែល ៤ រយកោដិជារៀង រាល់ឆ្នាំ។

### ពាក្យព្រលយ

- ✔ ជ្រើសហាង super-market ណាដែលយកថង់ប្លាស្ទីកវិញ។
- ✔ យកថង់ដែលអ្នកប្រើហើយទៅជាមួយនៅពេលទៅផ្សារ ហើយទុកថង់ មួយនៅក្នុងឡានប្រចាំការសំរាប់ពេលណាដែលខ្វះ។



## ៣ រក្សាឲ្យស្អាត

លាងជំរះប្រអប់ឬធុងណាដែលប្រឡាក់ម្ហូបអាហារ។ មិនត្រូវខ្ជះខ្ជាយទឹក។

-ប្រើទឹកដែលសល់ពីលាងចាន។

បន្ទុកគំនរក្រខ្វក់អាចត្រូវគេបដិសេធមិនយក។ វាអាចទាញបណ្តាលឲ្យមានសត្វតូចៗចង្រៃដូចជាកណ្តុរ ព្រមទាំងពីបាកខ្លាំងដល់អ្នកធ្វើការចែករំលែកនៅកន្លែងការងារ។

## ៤ ទិញយកវិញ

ធ្វើជាអ្នកបង្វិលប្រើឡើងវិញល្អជាការកិច្ចមួយ ក៏ប៉ុន្តែអ្នកក៏អាចធ្វើជាអ្នក បង្វិលប្រើឡើងវិញដ៏ល្អជាងគេ ដោយការទិញវត្ថុដែលធ្វើពីជាតិណាដែលបានបង្វិលប្រើឡើងវិញ។

ពេលអ្នកទិញរបស់របរ ចូររកមើលចំនួនជាតិបង្វិលប្រើឡើងវិញដែលមាន នៅនៅក្នុងរបស់របរនោះ ដូចជាប្រអប់ឬធុងប្លាស្ទីក គ្រឿខ្ចប់ ប្រអប់ ក្រដាសបង្គន់  ក្រដាសខ្ចប់និងក្រដាសចម្លង។




### ដកគម្របចេញ

គម្របធ្វើពីជាតិប្លាស្ទីកផ្សេងខុសពីដប៖ គេមិនអាចបង្វិលប្រើឡើងវិញឡើយ។



ដូច្នេះយកវាចេញហើយបោះចោលក្នុងធុងសំរាម។

មានបញ្ហាក្នុងការបង្វិលប្រើឡើងវិញ? សូមបើកមើលម្ខាងទៀតពីវិធី ដោះ ស្រាយបញ្ហាការបង្វឹលប្រើឡើងវិញ >>